N° 10
Reçu le 2-1-52
- Kampuchéak soriya -
INDOCHINE FRANÇAISE
RÉGIE DU DÉPÔT LÉGAL

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

...าเบ้ยชาติ
...ขาณฆาธ
...078.2

octobre

ឆ្នាំទី ២៣ ខែតុលា លេខ ១០

ព.ស. ២៤៩៤ — គ.ស. ១៩៥១

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| វគ្គសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ពុទ្ធសាសនានិងគ្រិស្តសាសនា (សន្និសីទ លោកវេជ្ជបណ្ឌិតមីតូត) (តមក)... | លោកប៉ាយ-ប៊ុក .......... | ៧២៣ |
| ពន្ធីអាស៊ីទ្វីប (តមក)............ | លោកប៉ាយ-ប៊ុក .......... | ៧២៧ |
| សម្មាទិដ្ឋិកថា .................. | ព្រះអាចារ្យ អាំ-សាមុល ..... | ៧៣១ |

**វគ្គអក្សរសាស្ត្រ**

| | | |
|---|---|---|
| រឿងមនុស្សថ្មី................. | លោកផេង-ជ្រីវ .......... | ៧៤១ |
| ការបណ្ដុះនិស្ស័យ (តមក)........ | ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម .... | ៧៥៦ |
| រឿងសាមកុក (តមក)............ | ឧកញ៉ា នូ-កន .......... | ៧៦៣ |
| ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក).. | ឧកញ៉ា ឈឹម-ក្រសេម...... | ៧៧១ |
| រឿងអារក្សថ្លែងរឿងថ្លៃប្រាំ (តមក).... | លោកសាង-សាភ៊ត......... | ៧៧៧ |

**កំណត់ទិនប្បវត្តិការណ៍**

| | | |
|---|---|---|
| ដំណើរមកកាន់ប្រទេសកម្ពុជានៃមហាបណ្ឌិត គុណាបាលបិយសេន ម៉ាឡាល៉ាសេកេរៈ (តចប់) | ពុទ្ធសាសនបណ្ឌិត្យ......... | ៧៨៧ |


មួយឆ្នាំមាន ១២ សៀវភៅ — ថ្លៃជាវ ១៥៥ ៛.០០

# សម្មាទិដ្ឋិកថា

## ព្រះអាចារ្យ អាំ-សាម៉ុល វត្តមហាមន្ត្រី ភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៤ រោចខែកត្តិកឆ្នាំកុរនព្វស័ក
ព.ស. ២៤៩០ ត្រូវនឹងថ្ងៃ ១២ ធ្នូ ឆ្នាំ ១៩៤៧

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះអរហំសម្មាសម្ពុទ្ធជាម្ចាស់ ព្រមទាំងព្រះសទ្ធម្មនឹងព្រះសង្ឃ ដោយសេចក្តីគោរព ។

ពេលនេះ អាត្មាភាពត្រូវវេនសំដែងធម្មទេសនាផ្សាយតាមវិទ្យុស័ព្ទ អាត្មាភាពនឹងសំដែងអំពី សម្មាទិដ្ឋិ គឺអង្គទី១ ក្នុងអដ្ឋង្គិកមគ្គ ដើម្បីចែកជូនពុទ្ធសាសនិកជន ដូចតទៅនេះ :–

ទិដ្ឋិ ប្រែថា "សេចក្តីយល់ឃើញ"; សម្មា ប្រែថា "ប្រពៃ, ត្រូវ" សម្មាទិដ្ឋិ ប្រែថា "សេចក្តីយល់ឃើញត្រូវ, យល់ឃើញប្រពៃ" ។ សម្មាទិដ្ឋិនោះ បានខាងបញ្ញា ដែលជាសោភនចេតសិកដ៏ក្លាហានតោងយកព្រះនិព្វានមកជាអារម្មណ៍ ដឹងច្បាស់ក្នុងអរិយសច្ចៈទាំង ៤ មានទុក្ខសច្ចៈជាដើម ហើយប្រតិបត្តិជីកគាស់រំលើងបង់នូវអវិជ្ជានឹងតណ្ហាឲ្យអស់ទៅ ។ សម្មាទិដ្ឋិនេះជាគូសត្រូវ ឬជាទំនាស់នឹងមិច្ឆាទិដ្ឋិ ។ ឯមិច្ឆាទិដ្ឋិ ប្រែថា "សេចក្តីយល់ឃើញខុស,

ពុំឃើញប្រពៃ" ។ ដែលពុំឃើញប្រពៃដូច្នេះតើមកអំពីអ្វី? គឺមកតែអំពីអវិជ្ជា ។ ឯសម្មាទិដ្ឋិ ដែលថាយល់ឃើញត្រូវនោះ ព្រោះមានវិជ្ជា ។

ចុះអវិជ្ជាជាឈ្មោះរបស់អ្វី? វិជ្ជាជាឈ្មោះរបស់អ្វី? ទោសនឹងអានិសង្សរបស់អវិជ្ជានឹងវិជ្ជានោះដូចម្តេច?

អវិជ្ជាជាឈ្មោះរបស់សេចក្តីមិនចេះដឹង, សេចក្តីមិនចេះមិនដឹង ហៅថា សេចក្តីល្ងង់, បើមិនចេះអក្សរនឹងលេខ ហៅថា ល្ងង់ក្នុងអក្សរនឹងលេខ, មិនចេះធ្វើការណា ហៅថា ល្ងង់ក្នុងការនោះ, បើមិនចេះគិត ហៅថា ល្ងង់ក្នុងការគិត, អ្នកណាមានសេចក្តីល្ងង់ អ្នកនោះឈ្មោះថាមនុស្សឥតមានចំណេះវិជ្ជា, អ្នកណាឥតមានចំណេះវិជ្ជា អ្នកនោះឈ្មោះថាមនុស្សល្ងង់ៗ នោះបើនឹងធ្វើការអ្វី ការនោះច្រើនតែមិនកើត បើទុកជាកើតក៏ច្រើនតែមិនល្អ, បើនឹងនិយាយពាក្យណា ពាក្យនោះច្រើនមិនប្រាកដ, បើនឹងគិតហេតុណា ហេតុនោះមិនចេញមកសំដែងឲ្យប្រាកដថាខុស ឬត្រូវបានទេ ។ មនុស្សល្ងង់ឧបមាដូចមនុស្សខ្វាក់ ធម្មតាមនុស្សខ្វាក់កម្រនឹងដើរតាមផ្លូវឲ្យត្រង់នឹងរហ័សឆាប់បានឡើយ ព្រោះមានសេចក្តីញញើតញញើមរញ្ញាកស្ទាក់ស្ទើរក្នុងចិត្តជានិច្ច ម្ល៉ោះហើយសេចក្តីមិនប្រាកដក្នុងចិត្តនោះ ធ្វើដំណើរមិនឲ្យប្រាកដថាទៅមុខ ឬទៅខាង ច្រើនទើសទាសដូចគ្នានឹងមនុស្សល្ងង់ បើនឹងធ្វើ ឬនិយាយ ឬគិត ក៏ឥតមានប្រាកដក្នុងចិត្ត. សេចក្តីមិនប្រាកដនេះឯង មិនអាចនឹងធ្វើប្រយោជន៍ដែលខ្លួនត្រូវការឲ្យសម្រេចបានឡើយ ។

មានពុទ្ធភាសិតមួយកន្លែងសំដែងថា: មោហៈគឺសេចក្ដីល្ងង់ បើមានច្រើនក្នុងសន្ដានចិត្តអ្នកណាមួយហើយ អាចនឹងធ្វើអ្នកនោះមិនឲ្យស្គាល់សេចក្ដីអាក្រក់ល្អនឹងការខុសត្រូវបានឡើយ ។

មានសុភាសិតមួយបទទៀតសំដែងថា

វិជ្ជាវិសេសលើសទ្រព្យធន ចោរមិនអាចប្លន់ឆក់លួចបាន
វិជ្ជាគ្មានថ្ងៃនឹងប្រមាណ ប្រើបេះតែបានគ្រប់វេលា ។

បណ្ដាទ្រព្យសម្បត្តិទាំងអស់ដែលមានក្នុងលោកនេះ ទោះជារបស់ឥតវិញ្ញាណដូចយ៉ាងលុយកាក់ប្រាក់កាសកែវកងជាដើមក្ដី ទោះជារបស់មានវិញ្ញាណដូចយ៉ាងខ្ញុំកំដរប្រុសស្រីគោក្របីសេះដំរីជាដើមក្ដីវិជ្ជាចំណេះការចេះដឹងក្នុងអក្សរ ក្នុងលេខនព្វន្តគុណហារ ក្នុងភាសាផងជាតិតាំងប្រទេសផ្សេងៗ ក្នុងការគូររក់សង្វាក់ក្បូរក្បាច់រចនា ចំណេះវិជ្ជាខាងហត្ថកម្មកសិកម្មវណិជ្ជកម្មជាដើមនេះឯង ប្រសើរវិសេសថ្លៃថ្លាជាងទ្រព្យសម្បត្តិគ្រប់មុខ ដែលជាទ្រព្យឥតវិញ្ញាណមានវិញ្ញាណនោះវិញ ព្រោះជាទ្រព្យសម្បត្តិទាំងនោះ មិនជារបស់មានខ្លឹមសារឋិតថេរយូរប៉ុន្មាន គង់មានវិនាសទៅដោយភ័យច្រើនប្រការ ដូចយ៉ាងភ័យអំពីចោរលួចប្លន់ឆក់ដណ្ដើម, ភ័យអំពីភ្លើងឆេះផ្ទះសម្បែង, ភ័យអំពីទឹកលិច, ឬវិនាសទៅដោយល្បែងបៀរប៉ោជាដើម ។ ឯចំណេះវិជ្ជានេះ ផុតស្រឡះអំពីភ័យទាំងឡាយមានចោរភ័យជាដើមនោះ គឺថាភ័យទាំងឡាយមានចោរភ័យ

ជាដើមនោះមិនអាចនឹងបៀតបៀនចំណេះវិជ្ជា ដោយការលួចប្លន់ឆក់ដណ្តើម ក៏ហែងនឹងគម្រាមម្ចាស់ចំណេះវិជ្ជានោះបានឡើយ ដោយហេតុនេះហើយបានជាពោលថា ចំណេះវិជ្ជានោះវិសេសថ្លៃថ្លាជាងទ្រព្យសម្បត្តិទាំងអស់ ។

ម្យ៉ាងទៀត ចំណេះវិជ្ជានេះ នឹងកាត់ថ្លៃថាមានដំឡៃប៉ុណ្ណេះប៉ុណ្ណោះ មិនទាំងបានផង, ព្រោះថាជនណាមួយជាអ្នកមានទ្រព្យសម្បត្តិធនធានច្រើន តែជាអ្នកខ្ជិលច្រអូសក្នុងការរៀនសូត្រ ជននោះចង់បានចំណេះវិជ្ជា ហើយយកប្រាក់កាសមានចំនួនច្រើនពាន់ច្រើនហ៊ឺន ទៅជួរប្តូរទិញ ចំណេះវិជ្ជានោះអំពីអ្នកណាមួយ ហើយប៉ង់នឹងផ្ញើចំណេះវិជ្ជានោះឲ្យរត់ចូលទៅក្នុងមាត់ឬក្នុងពោះ ដោយមិនបាច់រៀនសូត្រនោះមិនបានឡើយ កុំថាតែគ្រប់អ្នកមានចំណេះវិជ្ជានោះ នៅជាបុថុជ្ជនដូចយ៉ាងយើងរាល់រូបឡើយ សូម្បីតែព្រះលោកនាថជាម្ចាស់ ដែលព្រះអង្គជាឯកអគ្គបុគ្គលជាខ្ពើមផង ជាអង្គអរហន្តយ៉ាងថ្លៃថ្លា វិសេសទាំងអម្បាលម៉្លឹង ក៏ព្រះអង្គមិនអាចនឹងចាប់ទាញចំណេះវិជ្ជាជាលោកិយឬលោកុត្តរៈ ច្រកបញ្ចូលឲ្យចូលទៅក្នុងមាត់ឬក្នុងពោះនៃមនុស្សខ្ជិលនោះបានទេ កុំថាដល់ទៅចំណេះវិជ្ជាដែលធំៗ ដែលថ្លៃថ្លានោះឡើយ សូម្បីតែកំទេចកំទីចំណេះវិជ្ជា ដែលជារបស់ទន់ទាបថោកថយ នោះនឹងយកប្រាក់ចំនួនពាន់ហ៊ឺនទៅទិញក៏ពុំបាន តែខ្ជិលរៀនហើយកុំសង្ឃឹម មុខជាខានបានវិជ្ជា ។

ដោយហេតុនេះហើយបានជាថាចំណេះវិជ្ជាកាត់ថ្លៃមិនបាន ។ ម្យ៉ាងទៀត ទ្រព្យសម្បត្តិទាំងពួងប្រើចេះតែអស់ទៅៗតិចទៅៗ, បើមិនរកថែមទៀត បានតែខាងតាយម្យ៉ាងនោះ គង់មុខជាខានប្រើប្រាស់ ។ ឯចំណេះវិជ្ជាវិញមិនដូច្នោះទេ ប្រើប្រិនទៅគឺរឹងរឹតតែចំរើនឡើងៗ មិនចេះថយ មិនចេះស្រុត មិនចេះអស់, ដូចអ្នកចេះចំណេះវិជ្ជាខាងច្បាប់ទម្លាប់, អ្នកនោះ បើបានទៅសំដែងប្រាប់ឬពន្យល់អ្នកណា ឬទៅបង្រៀនគេហើយ ច្បាប់ទម្លាប់នោះ គង់រឹងរឹតតែចាំស្ទាត់ប្រាកដឡើង រឹងរឹតតែបែកព្រោងព្រាតឡើង; ឬក៏ដូចជាអ្នកចេះអក្សរកាព្យឃ្លោង, អ្នកនោះបើបានសំដែងប្រាប់ពន្យល់ ឬតែងញឹកញយហើយ អក្សរនិងកាព្យឃ្លោងនោះ គង់រឹងរឹតតែស្ទាត់ជំនាញសរសេររហ័សរហួន ឯកាព្យឃ្លោងកាន់តែពីរោះឡើងៗ បែកឡើងៗ លែងចាំបាច់នឹកនា ត្រាន់តែថាបានៗ ។ ដោយហេតុនេះហើយបានជាថា ចំណេះវិជ្ជាប្រើមិនចេះអស់ទេ ចេះតែចំរើនទៅខាងមុខជានិច្ច ។

មិនតែប៉ុណ្ណោះ ចំណេះវិជ្ជាអាចផ្តល់ប្រយោជន៍ឲ្យគ្រប់ពេលវេលា ដោយហេតុនេះហើយ បានជាថាចំណេះវិជ្ជានេះជាមិត្តទីមួយ របស់មនុស្សប្រុសស្រី ។ មួយវិញទៀត ចំណេះវិជ្ជាអាចនឹងធ្វើអ្នកទ្រទ្រង់ឲ្យគេកោតខ្លាចគោរពប្រណិប័តន៍ គឺថាជនណាមួយដែលមានពូជពង្សថោកទាប ឬមានរូបវិកលវិការៈយ៉ាងណាក៏ដោយ បើមានចំណេះវិជ្ជា

ចេះប្រើប្រាស់ស្រះស្រាយហើយ ជននោះបើទៅក្នុងទីណាមួយ ចំណេះវិជ្ជានេះ ក៏ហាក់ដូចជាទៅចាប់ទាញមនុស្សប្រុសស្រីឲ្យក្រោកចាកទីកន្លែងឡើង គោរពប្រណិប័តន៍កោតក្រែងចំពោះជននោះឯង ។

ម្យ៉ាងទៀតចំណេះវិជ្ជានេះ អាចនឹងធ្វើមនុស្សម្នាក់ឲ្យមានជីវិតស្មើនឹងមនុស្សមួយពាន់នាក់មួយម៉ឺននាក់ ឬច្រើនជាងនេះទៅទៀត សេចក្ដីនេះយ៉ាងណា? ថាដូចជាអ្នកណាមួយ ដែលគេចេះចំណេះផ្លូវលោកផ្លូវធម៌សព្វគ្រប់គ្មានចន្លោះ ព្រមទាំងចំណេះវិជ្ជាសម្រាប់ស្រុកប្រទេសរបស់ខ្លួន នឹងចំណេះវិជ្ជាសម្រាប់តាំងប្រទេសផ្សេងៗ ហើយអ្នកនោះក៏បានទទួលនូវឥស្សរភាពជាធំ បើប្រសិនជាមានកំហុសអ្វីគួរដល់បញ្ញាជន័យ-កម្មក្ដី គួរផ្ដាច់បង់ជីវិតក្ដី, មនុស្សប្រុសស្រីទាំងឡាយ ទាំងពាន់ម៉ឺននាក់ គួរប្រថុយជីវិតប្ដូរជំនួសមនុស្សម្នាក់នេះដែរ នេះដោយហេតុអ្វី? គឺដោយហេតុតែចំណេះវិជ្ជានេះហើយ ដែលធ្វើមនុស្សម្នាក់ឲ្យមានជីវិត ប្រ-ហែលនឹងមនុស្សទាំងពាន់ទាំងម៉ឺននាក់នេះឯង គួរឲ្យអស្ចារ្យណាស់ហ្ន៎! ចំណេះវិជ្ជានេះមានគុណប្រយោជន៍ច្រើនប្រការណាស់ ដោយហេតុនេះហើយ គួរតែសាធុជនប្រុសស្រីក្មេងចាស់គ្រហស្ថបព្វជិត ខំស្វះស្វែងរករៀនចំណេះវិជ្ជាផ្លូវលោកផ្លូវធម៌ ឲ្យបានចេះដឹងគ្រប់ៗគ្នាឡើង កុំគប្បីធ្វេសប្រហែសឡើយ ។

ម្យ៉ាងទៀតអ្នកដែលមានកូន ត្រូវពុកដាស់តឿនកូនឲ្យរៀនចំណេះវិជ្ជាឲ្យបានចេះដឹងឡើង ព្រោះកូនដែលគ្មានចំណេះវិជ្ជា ជាមនុស្ស

ល្ងង់មិនប្រព្រឹត្តតាមច្បាប់ នឹងមានប្រយោជន៍អ្វីដោយសារកូនដូច្នោះ
ប្រៀបដូចមាដូចក្អែកខ្វាក់ នឹងមានប្រយោជន៍អ្វីដោយក្អែកខ្វាក់នោះ
មានតែសេចក្តីអផ្សុកព្រួយចិត្តតែម្យ៉ាង ៗ

· កូនមាន ៣ គឺកូនដែលមិនទាន់កើត ១, កូនដែលកើតហើយស្លាប់បាត់ទៅវិញ ១, កូនដែលកើតហើយនៅរស់ តែជាមនុស្សល្ងង់ទៀត ១, បណ្តាកូនទាំង ៣ នេះ គួរយកកូន ២ ខាងដើម ព្រោះថាបើមានទុក្ខព្រួយក៏មានតែមួយលើកក៏បាត់ទៅ, ឯកូនមួយទីបំផុតនោះមិនគួរយកទេឡើយ ព្រោះកូននោះនឹងនាំបណ្តាលឲ្យមានសេចក្តីទុក្ខព្រួយជានិច្ច ៗ

ក្នុងគម្ពីរលោកនីតិបករណៈសំដែងថា ៖

មានកូនមិនឲ្យកូនសូត្ររៀន បំណោះរបៀនការនានា
មាតាលោកថាជាវេរ បិតាទុកជាសត្រូវធំ ៗ
កូនពេញរូបពាលពត់មិនទៀង ហៅថាមិនចេះក្នុងជំនុំ
ប្រៀបដូចកុកក្រោងចូលទ្រនំ កណ្តាលជំនុំនៃកងហង្ស ៗ

ដែលនាំសុភាសិតទាំងមកទុកក្នុងទីនេះ ដើម្បីឲ្យឃើញថា សេចក្តីល្ងង់នេះ បើកើតមានដល់អ្នកណាហើយ នឹងត្រឡប់ទៅជាទោស ធ្វើអ្នកនោះឲ្យបានដល់នូវសេចក្តីមិនចំរើន នឹងទន់ទាបថយថោក តាំងពីជាតិនេះដរាបដល់ជាតិខាងមុខ ៗ ឯទោសនៃសេចក្តីល្ងង់ដែលនឹងឃើញក្នុងជាតិនេះ ដូច្នេះ :—

១ – បើល្ងង់គ្មានវិជ្ជាអក្សរ គឺមិនចេះសរសេរ មិនចេះមើល ទាំងនាំឲ្យខាតបង់នូវប្រយោជន៍ផ្ទួនច្រើន គឺមិនអាចមើលសាស្ត្រា ឬសៀវភៅ ដែលមានច្បាប់ប្រដៅនាំឲ្យកើតគំនិតប្រាជ្ញា ឬមិនអាចសរសេរសំបុត្រ កត់ហេតុណានីមួយ ដែលខ្លួនត្រូវការផ្ញើទៅញាតិមិត្តបាន ។

២ – អ្នកដែលមិនមានចំណេះវិជ្ជាអ្វី បើនៅអាស្រ័យផ្អែកកោនគុនី សំណាក់អ្នកធំហើយ ចេះតែគោរពប្រណិប័តន៍យ៉ាងណាក៏ដោយ អ្នកធំនោះក៏មិនអាចលើកតំកើងអ្នកនោះ ឲ្យមានកេរ្តិ៍ឈ្មោះយសស័ក្តិបានឡើយ ព្រោះលោកយល់ថាជាមនុស្សល្ងង់ បើគ្រាន់បើណាស់ បានត្រឹមតែសេចក្ដីសុខជាន់ទាបប៉ុណ្ណោះ តែក៏គង់មិនរួចអំពីទីជាអ្នកបំរើគេដែរ ។

៣ – មនុស្សល្ងង់នោះ បើមានយសស័ក្តិ ដោយអំណាចព្រេងសំណាងជួយឧបត្ថម្ភ បើនិយាយការអ្វីទៅរកគេ គេពុំសូវជឿតាមពុំកោតខ្លាច ព្រោះគេដឹងថា ខ្លួនជាមនុស្សល្ងង់ ។

៤ – មនុស្សល្ងង់ ជាមនុស្សខ្វះមិត្តសំឡាញ់ ព្រោះគេមិនសូវត្រូវការយកខ្លួនធ្វើជាមិត្តសំឡាញ់ឡើយ ព្រោះហេតុអ្វី? ព្រោះគេដឹងថាខ្លួនជាមនុស្សល្ងង់ បើនឹងពឹងរកយកទៅធ្វើការអ្វី ឬជួយពិគ្រោះការអ្វីក៏មិនកើតទាំងអស់ បើទុកណាជាមានមិត្តសំឡាញ់ ក៏ច្រើនតែបានមិត្តសំឡាញ់ដែលជាមនុស្សល្ងង់ដូចគ្នា ។

៥ – មនុស្សល្ងង់បើជាអ្នករកស៊ី ក៏មិនអាចនឹងធ្វើសម្បត្តិឲ្យចំរើនដូចអ្នកដែលចេះដឹងបានឡើយ ព្រោះខ្លួនមិនស្គាល់កាលគួរនឹងកាលមិនគួរ ។

៦– មនុស្សល្ងង់មិនដែលបានសេចក្ដីសរសើរ អំពីសំណាក់អ្នកប្រាជ្ញណាមួយដល់ម្ដងឡើយ បើបានសរសើរខ្លះតែអំពីសំណាក់នៃមនុស្សល្ងង់ជាងខ្លួន ។ ទោសនៃសេចក្ដីល្ងង់សង្ខេបខ្លីតែប៉ុណ្ណោះ ។

អានិសង្សនៃការចេះដឹង ដែលឃើញច្បាស់ក្នុងជាតិនេះ ដូច្នេះ :–

១– បើចេះវិជ្ជាលេខឬអក្សរ គឺចេះសរសេរឬមើល នឹងនាំឲ្យមានប្រយោជន៍អាចមើលសាស្ត្រាឬសៀវភៅ ដែលជាច្បាប់ប្រដៅ នាំឲ្យកើតគំនិតប្រាជ្ញា ឬអាចសរសេរសំបុត្រកត់ហេតុណានីមួយ ដែលខ្លួនត្រូវការផ្ញើទៅញាតិមិត្របាន ។

២– អ្នកដែលមានចំណេះវិជ្ជា បើនៅធ្វើការក្នុងសំណាក់អ្នកធំ ដោយយកចិត្តទុកដាក់ អ្នកធំនោះលោកនឹងស្រឡាញ់រាប់អាន ហើយអាចទំនុកបំរុងឲ្យមានកេរ្តិ៍ឈ្មោះ យសស័ក្តិថ្កើងថ្កានឡើងបាន ព្រោះលោកយល់ថាខ្លួនមានចំណេះវិជ្ជា ។

៣– អ្នកមានចំណេះវិជ្ជា បើជាអ្នកមានយសស័ក្តិ ក៏មានសេចក្តីថ្កុំថ្កើងរុងរឿងក្នុងទីប្រជុំ បើនិយាយការអ្វីៗ គេក៏ជឿស្តាប់តាម ព្រោះគេយល់ថាជាអ្នកចេះ ។

៤– អ្នកចេះ ជាមនុស្សសម្បូណ៌ទៅដោយមិត្រសំឡាញ់ ព្រោះថាអ្នកឯទៀតគេច្រើនត្រូវការយកអ្នកមានចំណេះវិជ្ជានោះ ធ្វើជាទីពឹងក្នុងពេលដែលមានកិច្ចធុរៈអ្វីៗបាន ។

៥ – អ្នកចេះ បើតាំងខ្លួនជាអ្នករកស៊ីតាមធម្មតាវិញ ក៏មានសេចក្ដីចំរើនក្នុងការរកស៊ីនោះ ព្រោះជាអ្នកមានគំនិតចេះគិតស្គាល់ទំនងនៃការរកស៊ី មានស្គាល់ការគួរនិងមិនគួរជាដើម ។

៦ – អ្នកមានចំណេះវិជ្ជា រមែងបានទទួលនូវសេចក្ដីសរសើរ អំពីសំណាក់អ្នកប្រាជ្ញជារឿយៗ ។

ហេតុដូច្នេះ អស់លោកទាំងឡាយគួរចៀម គួរស្អប់សេចក្ដីល្ងង់ កុំបណ្ដោយចិត្តឲ្យសេចក្ដីល្ងង់ចូលមកលុកលុយបានឡើយ គួរតាំងសេចក្ដីព្យាយាម ប្រឹងប្រែងស្វះស្វែងរករៀនចំណេះវិជ្ជា មកទុកដាក់ក្នុងខ្លួន ដើម្បីនឹងបំបាត់បង់នូវសេចក្ដីល្ងង់ចេញបន្តិចម្ដងៗ ជាលំដាប់តទៅ ។

វិជ្ជាជាឈ្មោះរបស់សេចក្ដីចេះដឹង បើអ្នកណាមានចំណេះវិជ្ជាហើយ អ្នកនោះរមែងបាននូវអានិសង្សដូចពណ៌នាមកនេះ ។ ហេតុដូច្នេះ ចូរពួកយុវជន យុវនារីទាំងឡាយ ខំរករៀនចំណេះវិជ្ជា ឲ្យបានចេះដឹងមាំមួនដើម្បីនឹងជួយជ្រោមជ្រែងជាតិ សាសនា មហាក្សត្រ របស់យើងឲ្យបានចំរើនរុងរឿង ឲ្យបានដើរទាន់សម័យនឹងគេឡើង ។

អាត្មាភាពសំដែងអរិយមគ្គទី ១ គឺសម្មាទិដ្ឋិ ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។